# ម៉ាថាយ ១០:៣៧-៣៩



សូមសិក្សារួមគ្នាជាដៃគូ ឬជាក្រុមតូចៗនូវខគម្ពីរដែលបានចាត់ឲ្យ ហើយពិភាក្សាពីចម្លើយរបស់អ្នកចំពោះសំណួរនានា ។

សូមអាន ម៉ាថាយ ១០:៣៧–៣៨ដោយរកមើលការលះបង់ដែលព្រះអង្គសង្គ្រោះបានមានបន្ទូលថា យើងត្រូវព្រមធ្វើដូចជាពួកសាវករបស់ទ្រង់ដែរ ។ ឃ្លាថា « គួរនឹងខ្ញុំ » នៅក្នុងខគម្ពីរទាំងនេះមានន័យថា អ្នកតំណាងដ៏សក្តិសមមួយរូបរបស់ព្រះអម្ចាស់ ហើយសក្តិសមនឹងពរជ័យរបស់ទ្រង់ ។

- ហេតុអ្វីអ្នកគិតថា វាជាការចាំបាច់សម្រាប់ពួកសាវករបស់ព្រះយេស៊ូវគ្រីស្ទត្រូវស្រឡាញ់ទ្រង់លើសអ្វីៗផ្សេងទៀត—រួមបញ្ចូលទាំងសមាជិកគ្រួសាររបស់ពួកគេផងដែរ ?

ពាក្យ ឈើឆ្កាង ដែលបានលើកឡើងក្នុង ខទី ៣៨ និយាយទៅដល់ឈើឆ្កាងដែលព្រះយេស៊ូវគ្រីស្ទបានលី ហើយត្រូវបានលើកឡើងដើម្បីបំពេញតាមព្រះទ័យរបស់ព្រះវរបិតាទ្រង់ ។ ក្នុងន័យធៀបព្រះយេស៊ូវគ្រីស្ទបានអំពាវនាវឲ្យពួកអ្នកដើរតាមទ្រង់ « ផ្ទុកឈើឆ្កាងខ្លួនមកតាម [ ទ្រង់ ] » ( ម៉ាថាយ ១៦:២៤ ) ។

សូមអានការបកប្រែដោយយ៉ូសែប ស្ម៊ីធ ម៉ាថាយ ១៦:២៦ ( នៅក្នុង សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ) ហើយរកមើលអត្ថន័យរបស់វាចំពោះយើងក្នុងការផ្ទុកឈើឆ្កាងរបស់យើង ហើយដើរតាមព្រះយេស៊ូវគ្រីស្ទ ។

សូមអាន ម៉ាថាយ ១០:៣៩ដោយរកមើលគោលការណ៍ ដែលព្រះយេស៊ូវគ្រីស្ទបានបង្រៀនអំពីការលះបង់ ។ ការបកប្រែដោយយ៉ូសែប ស្ម៊ីធ បញ្ជាក់ពីការចាប់ផ្តើមនៃខគម្ពីរនេះថា « អ្នកដែលចង់ឲ្យរួចជីវិត . . . » ) ។ នៅក្នុងបរិបទនេះ ឃ្លាថា « រួចជីវិត » មានន័យថាការរស់នៅដោយកំណាញ់ជាជាងខិតខំបម្រើព្រះ និងកូនចៅរបស់ទ្រង់ ។

- តើអ្នកគិតថា មនុស្សដែលផ្តោតលើបំណង និងក្តីប្រាថ្នាដ៏កំណាញ់របស់ខ្លួន នៅទីបំផុតនឹង « បាត់ » ជីវិតទៅដោយរបៀបណា ?

យោងតាមអ្វីដែលអ្នកបានអាន សូមបំពេញគោលការណ៍ខាងក្រោម ៖

**ប្រសិនបើយើងខិតខំដើម្បីបានរួចជីវិតនោះ** ________________________________________ ។

សូមពិចារណាគូសចំណាំនៅក្នុង ខទី ៣៩ នូវសន្យាដែលព្រះអង្គសង្គ្រោះបានធ្វើដល់អស់អ្នកដែលបានបាត់ជីវិតសម្រាប់កិច្ចការរបស់ទ្រង់ ។ ការបាត់ជីវិតសម្រាប់កិច្ចការរបស់ទ្រង់ គឺលើសពីការសុខចិត្តស្លាប់ដើម្បីទ្រង់ទៅទៀត ។ វាមានន័យថា ការយល់ព្រមថ្វាយខ្លួនយើងរាល់ថ្ងៃដើម្បីបម្រើទ្រង់ និងមនុស្សដែលនៅជុំវិញយើង ។

- តើអ្នកគិតថា កាលដែលយើងរកឃើញជីវិតមកវិញ នៅពេលយើងបាត់ជីវិតសម្រាប់ទ្រង់នោះមានន័យដូចម្តេច ?

យោងតាមអ្វីដែលអ្នកបានអាន សូមបំពេញគោលការណ៍ខាងក្រោម ៖

**ប្រសិនបើយើងបាត់ជីវិតសម្រាប់ព្រះយេស៊ូវគ្រីស្ទ នោះ** ________________________________________ ។

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ថូម៉ាស អេស ម៉នសុន រួចពិភាក្សាចម្លើយរបស់អ្នកសម្រាប់សំណួរបន្ទាប់ពីនោះ ។



« ខ្ញុំជឿថា ព្រះអង្គសង្គ្រោះកំពុងតែប្រាប់យើងថា លើកលែងតែយើងលះបង់ខ្លួនយើង ដើម្បីបម្រើដល់អ្នកដទៃ នោះទើបជីវិតរបស់យើងផ្ទាល់នឹងមានគោលបំណងបន្តិចបន្តួចវិញ ។ អ្នកទាំងឡាយណាដែលរស់នៅសម្រាប់តែខ្លួនឯង ទីបំផុតនឹងហួតហែង ហើយមាននិមិត្តរូបជា ការបាត់ជីវិតរបស់ខ្លួន ខណៈដែលមនុស្សដែលបាត់បង់ខ្លួនពួកគេដើម្បីបម្រើអ្នកដទៃ នឹងរីកចម្រើន ហើយលូតលាស់—និងជាប្រយោជន៍សំរាប់សង្គ្រោះ ជីវិតរបស់ពួកគេវិញ » ( « What Have I Done for Someone Today ? » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៨៥ ) ។

- តើមនុស្សដែលអ្នកស្គាល់ដែលបានជ្រើសរើសបាត់បង់ជីវិតសម្រាប់ព្រះយេស៊ូវគ្រីស្ទជានរណា ? តើការសម្រេចចិត្តនេះមានផលប៉ះពាល់អ្វីខ្លះចំពោះបុគ្គលនេះ ?



© ២០១៥ ដោយ Intellectual Reserve, Inc. រក្សាសិទ្ធិគ្រប់យ៉ាង ។